**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៦២៤ ក.ប / [illegible]

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើស ឬប្រឡងជ្រើសរើសសិស្ស-និស្សិតថ្នាក់អាហារូបករណ៍ និងថ្នាក់បង់ថ្លៃឱ្យចូលរៀន នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំសិក្សា ២០១២-២០១៣

យោងតាមស្មារតីអង្គប្រជុំស្តីពីការកំណត់កាលបរិច្ឆេទ និងកំណត់ចំនួនជ្រើសរើស ឬប្រឡងជ្រើសរើសសិស្ស-និស្សិតថ្នាក់អាហារូបករណ៍ និងថ្នាក់បង់ថ្លៃ ឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំសិក្សា ២០១២-២០១៣ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹងថា នៅក្នុងឆ្នាំសិក្សា ២០១២-២០១៣ ខាងមុខនេះ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនឹងធ្វើការជ្រើសរើស ឬប្រឡងជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមគោលការណ៍ដូចមាននៅក្នុងតារាង ៖

**កាលបរិច្ឆេទ និងចំនួនជ្រើសរើស ឬប្រឡងជ្រើសរើសសិស្ស-និស្សិត**
**នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំសិក្សា ២០១២-២០១៣**

| ល.រ | គ្រឹះស្ថានសិក្សា | ចំនួនជ្រើសរើស | | | | | | | | កាលបរិច្ឆេទប្រឡង ឬជ្រើសរើស (អាហារូបករណ៍) |
|---|---|---|---|---|---|---|---|---|---|---|
| | | ក្រោយឧត្តម | | ឧត្តម | | បរិញ្ញា | | បឋម | | |
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ១ | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | | ១៥០ | ២០០ | ៥៤០ | ៣៦០ | ៤០០ | | | ០២-១០-១២ |
| ២ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | | ៤០ | ២៥០ | ៤០០ | ៥០ | ៥០០ | ៧៥ | | ២៣-១០-១២ |
| ៣ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | | ១២០ | ២៤០ | ២៤០ | ២៤០ | ២៤០ | ១២០ | | ១៩-១០-១២<br>២៦-១០-១២ |
| ៤ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | | | | ៣៣០ | | ១៦០ | | ២៥ | ០៤-១១-១២ |
| ៥ | វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម | | | ២៥ | ២៥ | ១០៥ | ១០៥ | ១០៥ | | ២៩-១០-១២<br>០១-១១-១២ |
| ៦ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា | | | ១៣៥ | ៤២០ | ៥០ | ១៥០ | ៦០ | ៦០ | ១២-១០-១២<br>២២-១០-១២ |
| ៧ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត | | | ១៥០ | ១៥០ | ៤០ | ៤០ | ១២០ | | ០១-១១-១២<br>១១-១១-១២ |
| ៨ | វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង | | | | ៤០ | ៧៥ | ៦០ | ១២០ | ៧៥ | ០៣-១២-១២<br>១២-១២-១២ |

| ល.រ | គ្រឹះស្ថានសិក្សា | ចំនួនជ្រើសរើស | | | | | | | | កាលបរិច្ឆេទប្រឡងជ្រើសរើស (អាហារូបករណ៍) |
|---|---|---|---|---|---|---|---|---|---|---|
| | | ក្រោយឧត្តម | | ឧត្តម | | មធ្យម | | បឋម | | |
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ៩ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង | | | ៥០ | ៥០ | ៥០ | ៥០ | ៥០ | | ១២-១១-១២<br>២២-១១-១២ |
| ១០ | សាលាមធ្យមសិក្សាបច្ចេកទេស ហ៊្សុី វ៉េ សេ | | | | | ៣០ | ២០ | ១០០ | ៥០ | ២៨-០៩-១២<br>០៩-១០-១២ |
| ១១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល | | | | | | | ៧០ | | ០៥-១២-១២ |
| ១២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ | | | | | ១២០ | ១២០ | ៥០ | ៥០ | ២៦-១១-១២<br>២៥-១២-១២ |
| ១៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម | | | | | ៥០ | ១៥០ | ៦០ | | ២០-១១-១២<br>១៨-១២-១២ |
| ១៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ | | | | | ១០០ | ១០០ | ៥០ | ៥០ | ០៥-១០-១២<br>១២-១២-១២ |
| ១៥ | មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ | | | | | | | ៦០ | ៣០ | ០៧-១២-១២ |
| ១៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការស្ថិតិ | | | | | | | | | ២៦-១១-១២ |
| ១៧ | សាលាជាតិកសិកម្មព្រែកលៀប | | | ២២៥ | ៧០ | ១៣០ | ៨០ | | | ០១-១០-១២ |
| ១៨ | សាលាបច្ចេកទេសផលិតអវៈយវៈសិប្បនិម្មិត និងរណបកម្ពុជា | | | | | ០៤ | | | | ១២-០៩-១២ |
| ១៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង | | | | | ៦០ | ៥០ | ៥០ | ៦០ | ២៥-០៩-១២<br>២៥-១០-១២ |
| ២០ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ | | | | | | | ៣០ | | ០៥-១១-១២ |
| ២១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិសាត់ | | | | | ៧៥ | ៧៥ | ៥០ | ៥០ | ០១-១១-១២<br>១៥-១១-១២ |
| ២២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | | | | | ២៥ | ៥០ | ៥០ | ៧៥ | ០១-១១-១២<br>២៨-១២-១២ |
| ២៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ | | | | | ១៥០ | ១៥០ | ៧៥ | ៧៥ | ០១-១០-១២<br>១៦-១១-១២ |
| ២៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង | | | | | ១០០ | ៧៥ | ៥០ | ៥០ | ២៦-១០-១២<br>១២-១១-១២ |
| ២៥ | ការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | | | | | ២០ | ២០ | ៤០ | ៤០ | ២៣-១០-១២<br>០៨-១១-១២ |
| ២៦ | វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា | | | | ៦០០ | | ៤៥០ | | | ២៤-១២-១២ |
| ២៧ | វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច | | ៥០ | ១០០ | ២០០ | ១០០ | ២០០ | | | ១៨-០៩-១២<br>១៩-១១-១២ |
| ២៨ | វិទ្យាស្ថានខ្មែរជំនាន់ថ្មី | | | ៥០០ | ១៥០០ | ២០០ | ៨០០ | | | ០១-១០-១២<br>១២-១១-១២ |
| ២៩ | វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា | | ១០០ | ៣០០ | ៧០០ | ១០០ | ២០០ | | | ១៣-០៩-១២ |
| ៣០ | វិទ្យាស្ថានអនាគតយុវជនកម្ពុជា | | | | | | ៣០០ | | | ២៥-១០-១២ |

| ល.រ | គ្រឹះស្ថានសិក្សា | ចំនួនជ្រើសរើស | | | | | | | | កាលបរិច្ឆេទប្រឡង ឬជ្រើសរើស (អាហារូបករណ៍) |
|---|---|---|---|---|---|---|---|---|---|---|
| | | ក្រោយឧត្តម | | ឧត្តម | | មធ្យម | | បឋម | | |
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ៣១ | វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត | | | | | ២០០ | ២០០ | | | ១២-១២-១៦ |
| ៣២ | វិទ្យាស្ថានប៉ូលីតិចអន្តរជាតិ | | | | | ១០០ | ១៥០ | | | ១៣-១២-១៦ |
| ៣៣ | អង្គការមូលនិធិដុនបូស្កូកម្ពុជា | | | | | | | ២៧៨ | | ១៣-០៨-១៦ |
| ៣៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូទាវទួលគោក | | | | | ៨០ | | | | ០៣-០៦-១៦ |
| ៣៥ | សាលាបច្ចេកទេសដុនបូស្កូខេត្តព្រះសីហនុ | | | | | ៣១៥ | | | | ១៧-០៨-២០១៦ |
| ៣៦ | សមាគមសម្រស់កត្តាកុមារខ្មែរ (សាលាជាងឈើ ESK) | | | | | | | ២៥ | | ២៤-០៨-១៦ |
| ៣៧ | វិទ្យាស្ថាន PSE | | | ១៥០ | | | | ៩៥៣ | | ០១-០៨-១៦<br>០៦-១១-១៦ |
| ៣៨ | វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្សអាស៊ីនៅកម្ពុជា | | | | | ១០០ | | | | ០៣-១១-១៦ |
| ៣៩ | វិទ្យាស្ថានបច្ចេកទេសជួសជុលរថយន្ត | | | | | ០៥ | ១១៥ | | ៣៥០ | ១២-១២-១៦ |

## ១. លក្ខខណ្ឌចុះឈ្មោះប្រឡង ឬជ្រើសរើស

- កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស និស្សិតអាចចុះឈ្មោះជាបេក្ខជនបាន លុះត្រាតែមានសញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រមានតម្លៃស្មើ ។
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស និស្សិតអាចចុះឈ្មោះជាបេក្ខជនបាន លុះត្រាតែមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ។
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស និស្សិតអាចចុះឈ្មោះជាបេក្ខជនបាន លុះត្រាតែមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (សម្រាប់ថ្នាក់បង់ថ្លៃ) ឬសញ្ញាបត្រមានតម្លៃស្មើ ។
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ សិស្សដែលអាចចុះឈ្មោះជាបេក្ខជនបាន លុះត្រាតែមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬលិខិតបញ្ជាក់ការសិក្សាថាបានរៀនចប់ថ្នាក់ទី៩ នៃសាលាចំណេះទូទៅ ឬវិញ្ញាបនបត្រកម្មវិធីស្ពានចម្លងបន្តជំនាញ។

## ២. សំណុំលិខិតរបស់បេក្ខជន

១. ពាក្យសុំចូលរៀននៅក្នុងគ្រឹះស្ថានសិក្សា ចំនួន ០១ ច្បាប់

២. ចំពោះកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រ មានតម្លៃស្មើ ចំនួន ០១ ច្បាប់

៣. ចំពោះកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស បេក្ខជនត្រូវមានព្រឹត្តិបត្រពិន្ទុនៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ចំនួន ០១ច្បាប់

៤. ចំពោះកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស

បេក្ខជនត្រូវមានព្រឹត្តិបត្រពិន្ទុប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់ថាបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (សម្រាប់ថ្នាក់បង់ថ្លៃ) ឬសញ្ញាបត្រមានតម្លៃ ស្មើ ចំនួន ០១ ច្បាប់

៥. កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬលិខិតបញ្ជាក់ការសិក្សាថាបានរៀនចប់ថ្នាក់ទី៩ នៃសាលាចំណេះទូទៅ ឬវិញ្ញាបនបត្រកម្មវិធីស្ពានចម្លងបន្តជំនាញ ចំនួន ០១ ច្បាប់

៦. ប្រវត្តិរូបដែលមានបិទរូបថត (៤ x ៦ ស.ម) ចំនួន ០២ ច្បាប់ (ប្រវត្តិរូបត្រូវមានបញ្ជាក់ពីនាយកសាលា)

៧. រូបថតក្នុងពេលថ្មីៗទំហំ (៤ x ៦ ស.ម) ចំនួន ០៣ សន្លឹក

បេក្ខជនដែលមានស្ថានភាពគ្រួសារក្រីក្រ និងអ្នករស់នៅតំបន់ដាច់ស្រយាល ដែលបានចាត់ទុកជាអាទិភាពក្នុងការទទួលអាហារូបករណ៍ ត្រូវមានឯកសារពីរបន្ថែមទៀតគឺ សេចក្តីបញ្ជាក់ត្រឹមត្រូវពីរដ្ឋអំណាចថ្នាក់ឃុំ ឬសង្កាត់អំពីភាពក្រីក្រ និងអាសយដ្ឋានរស់នៅតំបន់ដាច់ស្រយាល ប័ណ្ណគ្រួសារថតចម្លងតាមផ្លូវច្បាប់ ចំនួន ០១ ច្បាប់ ។

គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗមានបំណងធ្វើការជ្រើសរើស ឬប្រឡងជ្រើសរើស ត្រូវធ្វើសេចក្តីជូនដំណឹងលម្អិតដោយឡែករបស់ខ្លួន ។

ចំពោះព័ត៌មានផ្សេងៗទៀត បេក្ខជនអាចធ្វើការទំនាក់ទំនងផ្ទាល់ជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗដែលខ្លួនមានបំណងចុះឈ្មោះជ្រើសរើស ឬប្រឡងជ្រើសរើស ។៚

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១២

រដ្ឋមន្ត្រី

វង សូត

<u>ចម្លងជូន</u> :

- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ស្ថាប័ន ក្រសួង មន្ទីរ និងអង្គភាពពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួង ក.ប
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
  "ដើម្បីអនុវត្ត និងជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ